ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែសីហា ឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែសីហា ឆ្នាំ២០១៥នេះ ដំណើរការការងារបង្កបង្កើនផលស្រូវរដូវវស្សានៅទូទាំងប្រទេស សម្រេចបានចំនួន២.១២៣.៦២៩ហិកតា ស្មើនឹង៨២,៧២% នៃផែនការ២.៥៦៧.១៣០ហិកតា (តិចជាងឆ្នាំមុន៦០.៧៥១ហិកតាគិតក្នុងរយៈពេលដូចគ្នា)។ មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយល្អនៅទូទាំងប្រទេស តែនៅតាមតំបន់ខ្លះ ភ្លៀងធ្លាក់តិចតួចនិងពុំមានទឹកគ្រប់គ្រាន់នៅឡើយ។ ខេត្តដែលដាំដុះបានលឿនជាងគេគឺខេត្តបន្ទាយមានជ័យ ១០០,៨៣% ហើយខេត្តដែលអនុវត្តបានតិចជាងគេគឺខេត្តប៉ៃលិន៤៥,១៨%។

គួរកត់សម្គាល់ថា ការភ្ជួររាស់ដោយគ្រឿងយន្តក្នុងទូទាំងប្រទេសមានអត្រាប្រមាណ៨៩,៥៩%។ រីឯការភ្ជួររាស់ដោយកម្លាំងសត្វពាហនៈនៅសល់ក្រោម១០,៤១% ប៉ុណ្ណោះ។ ឆ្នាំនេះ ប្រជាកសិករចូលចិត្តបង្កបង្កើនផលស្រូវដោយព្រោះយកតែម្តងច្រើនជាងការដកស្ទូង ម្យ៉ាងមកពីការរាំងស្ងួតអូសបន្លាយយូរនៅដើមរដូវ និងដោយសារខ្វះកម្លាំងពលកម្មផងដែរ។

ដោយឡែក ចំពោះជំងឺឆ្លងសត្វមានផ្ទុះករណីជំងឺផ្ដេកត្រចៀកខៀវនៅចុងខែសីហា ស្ថិតនៅក្នុងខេត្តកំពង់ចាម ខេត្តស្វាយរៀង និងខេត្តសៀមរាប ដែលថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអង្គភាពជំនាញបានចុះអន្តរាគមន៍ធ្វើការផ្សព្វផ្សាយ និងចាត់វិធានការតាមគ្រប់រូបភាពក្នុងការធ្វើអនាម័យសត្វ ការធ្វើជីវសុវត្ថិភាព ការការពារជំងឺឆ្លងសត្វផ្សេងៗ និងដើម្បីសុខភាពសាធារណៈ។

លទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំឆ្នាំ ក៏ដូចជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មដែលសម្រេចបានក្នុងខែសីហា ឆ្នាំ២០១៥នេះ មានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ លទ្ធផលការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាឆ្នាំ២០១៥

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន៣.២០៣.៨១៥ហិកតា ក្នុងនោះភ្ជួររាស់ដោយគោ ក្របីចំនួន៣៣៣.៦២៤ហិកតា ស្មើនឹង១០,៤១% និងគ្រឿងយន្តចំនួន២.៨៧០.១៩១ហិកតា ស្មើនឹង៨៩,៥៩% លើសឆ្នាំមុនចំនួន៦២៨.៣៣០ហិកតា
- ផ្ទៃដីសាបសម្រេចបានចំនួន៦៥.៣២៩ហិកតា តិចជាងឆ្នាំមុនចំនួន៤៣.៨៥៩ហិកតា
- ផ្ទៃដីសន្ទូងនិងពង្រោះសម្រេចបានចំនួន២.១២៣.៦២៩ហិកតា ស្មើនឹង៨២,៧២% នៃផែនការ២.៥៦៧.១៣០ហិកតា តិចជាងឆ្នាំមុនចំនួន៦០.៧៥១ហិកតា ក្នុងនោះស្រូវពង្រោះនិងស្រូវចម្ការ១.៨៧០.៨៩១ហិកតា ស្មើនឹង៨៨,១០% ស្រូវសន្ទូងមាន២៥២.៧៣៨ហិកតា ស្មើនឹង១១,៩០% នៃផ្ទៃដីអនុវត្ត២.១២៣.៦២៩ហិកតា និងស្រូវតាមប្រភេទមាន៖

  + ស្រូវស្រាលចំនួន៤៧៩.៧២៤ហិកតា (ក្នុងនោះ ស្រូវបង្កើនរដូវចំនួន១៣៤.៧២៣ហិកតា) តិចជាងឆ្នាំមុនចំនួន៨០.៦៩២ហិកតា
  + ស្រូវកណ្តាលចំនួន១.០៦០.៧៧៤ហិកតា លើសឆ្នាំមុនចំនួន២១.២៩០ហិកតា
  + ស្រូវធ្ងន់ចំនួន៥០២.៥១២ហិកតា លើសឆ្នាំមុនចំនួន១៤.៤៨២ហិកតា

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
No. 200 Preah Norodom Blvd. Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

+ ស្រូវចម្ការចំនួន៣៤.៧១៣ហិកតា តិចជាងឆ្នាំមុនចំនួន៩.២៦៤ហិកតា

+ ស្រូវឡើងទឹកចំនួន៤៥.៩០៦ហិកតា តិចជាងឆ្នាំមុនចំនួន៦.៥៦៧ហិកតា។

**១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម**

- ផ្ទៃដីដំណាំរួមផ្សំសម្រេចបានចំនួន៦៨៣.៤៤៤ហិកតា ស្មើនឹង១២២,១៤% នៃផែនការ៥៥៩.៥៥០ហិកតា លើសឆ្នាំមុនចំនួន៤៥.៤៣១ហិកតា

- ផ្ទៃដីដំណាំឧស្សាហកម្មសម្រេចបានចំនួន១០១.៧៩៩ហិកតា ស្មើនឹង៧៨,៤៦% នៃផែនការ១២៩.៧៤២ហិកតា តិចជាងឆ្នាំមុនចំនួន១៤.១៥០ហិកតា។

**១.៣ ល្បឿនការងារប្រមូលផលស្រូវស្រាលដើមរដូវវស្សាឆ្នាំ២០១៥**

ការងារប្រមូលផលស្រូវស្រាលដើមរដូវសម្រេចបានចំនួន៩៦.៩០៧ហិកតា លើផ្ទៃដីអនុវត្តសរុបចំនួន៤៧៩.៧២៤ ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន៣៣៩.៨៥៩តោន តិចជាងឆ្នាំមុន១៨៤.៦០១តោន និងទិន្នផលជាមធ្យមចំនួន៣,៥០៧តោនក្នុងមួយហិកតា តិចជាងឆ្នាំមុន២៤៣គីឡូក្រាមក្នុងមួយហិកតា។

**១.៤ ការនាំចេញអង្ករ**

គួរកត់សម្គាល់ថា ការនាំចេញអង្ករកម្ពុជាក្នុងរយៈពេល៨ខែដើមឆ្នាំ២០១៥នេះ មានបរិមាណចំនួន៣៤២.១៣៦ តោន ដែលមានការកើនឡើងចំនួន១៩៨.២៧៧តោន(+៤៦,៣%) លើសបរិមាណនាំចេញក្នុងរយៈពេល៨ខែដើមឆ្នាំ ២០១៤ (ដែលមានតែ២៣៣.៨៥៩តោន)។ ដោយឡែកបរិមាណនាំចេញក្នុងខែសីហា ឆ្នាំ២០១៥នេះ មានតែ២៩.៨១៩ តោន ដែលមានការថយចុះចំនួន៥២តោន(-០,២%)តិចជាងបរិមាណនាំចេញក្នុងខែសីហា ឆ្នាំ២០១៤ ដែលមាន២៩.៨៧១ តោន និងនាំចេញទៅកាន់ទិសដៅចំនួន៥៤ប្រទេស។

**១.៥ ស្ថានភាពប៉ះពាល់និងខូចខាតដោយគ្រោះធម្មជាតិ**

គ្រោះខ្វះទឹកប៉ះពាល់លើផ្ទៃដីសរុបចំនួន១៨៥.៤៥១ហិកតា ក្នុងនោះមានសំណាបសរុបចំនួន២.៥៨២ហិកតា និងសន្ទូង-ពង្រោះសរុបចំនួន១៨២.៨៦៩ហិកតា។ សំណាបខូចខាតចំនួន៦៤ហិកតា សន្ទូង-ពង្រោះខូចខាតចំនួន ៩.១៧៦ហិកតា។

| ល.រ | រាជធានី-ខេត្ត | ប៉ះពាល់(ហត) | | ខូចខាត(ហត) | | ស្តារបាន(ហត) | |
|---|---|---|---|---|---|---|---|
| | | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ | សំណាប | សន្ទូង-ពង្រោះ |
| ១ | បន្ទាយមានជ័យ | 26 | 67,759 | - | 1,050 | | |
| ២ | បាត់ដំបង | - | 56,779 | - | 7,875 | | |
| ៣ | កំពង់ចាម | 87 | 3,755 | - | - | | |
| ៤ | កំពង់ឆ្នាំង | 487 | 2,920 | - | 88 | | |
| ៥ | កំពង់ស្ពឺ | 1,712 | 3,813 | 64 | - | | |
| ៦ | កំពង់ធំ | - | 4,390 | - | - | | |
| ៧ | កណ្តាល | 245 | 1,175 | - | - | | |
| ៨ | ភ្នំពេញ | - | 170 | - | - | | |
| ៩ | ព្រៃវែង | 15 | 2,513 | - | - | | |
| ១០ | ពោធិ៍សាត់ | - | 24,387 | - | 163 | | |
| ១១ | ស្វាយរៀង | - | 12,039 | - | - | | |
| ១២ | តាកែវ | 10 | 8,280 | - | - | | |
| ១៣ | ឧត្តរមានជ័យ | - | 1,642 | - | - | | |
| សរុប | | 2,582 | 189,622 | 64 | 9,176 | | |

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៤៤,៣១ | ៤០៦,៣៨ | ៣៤៩,០០ |
| សរុប I | | ៤០៦,៦០ | ៣៤៤,៣១ | ៤០៦,៣៨ | ៣៤៩,០០ |
| II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អ៊ិនវេសមេន គ្រុប | ១១.៦១៨,៣៧ | ៤.៤០៩,៤៤ | ១៣.១៣៧,០៨ | ១០.៦៣៣,៩៤ |
| ២ | ក្រុមហ៊ុន ស៊ីហ្វវ៉ាប់ប៊េលីមីធីត (រតនគិរី) | ៧៨,៥៣ | ២.០៦៤,៣០ | ១០៤,០៨ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៨០ | ១.០៥៧,១២ | ៦៥២,៨៤ | ៣២០,០០ |
| ៤ | ក្រុមហ៊ុន ឡុង ស្រេង | ២.៦៤៥.៩៧ | ៣.០៦៥,៣៨ | ៤.០៥១,៧២ | ៣.៣៦២,២០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៥.៣៤៦,៦៩ | ២.៣៩៧,៩៣ | ១.៥០០,៩៦ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វវីសសស៍ (ស្នួល) | ១.៧៤៤,៧៨ | ២.៦៤១,៤៣ | ១.៣៧៧,០៩ | ១.០៣០,០០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.០២៩,៧០ | ១.២៣៧,៥៩ | ៨៦២,៩៦ | ៤៨៥,២០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣.១១១,៦៥ | ១.២១៥,៥៥ | ១.០៥៩,៣១ | ៧១៤,៨០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (មេមសហេក) | - | ៨៧៥,៦៦ | - | - |
| ១០ | ក្រុមហ៊ុនក្រេក (ខេមបូឌា) ខូអិលធីឌី | ៣.២៥៦,០៩ | ២.៤៧៥,៣៨ | ៣.៣៥៩,៩៤ | ២.១៤៣,៤០ |
| សរុប II | | ២៨.៩៩៥,៦៣ | ២៤.៣៨៨,៥៤ | ២៧.០០២,៩៥ | ២០.១៩០,៥០ |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៦.៤១៥,០០ | ១៥៥.២៦២,០០ | ២.៧៧២,០០ | ២.៧៧២,០០ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៧៣.៣៩៦,០០ | ៦៦.៩៥០,០០ | ៤៣.៨០៧,០០ | ៤២.៤៣១,០០ |
| សរុប III | | ៧៩.៨១១,០០ | ២២២.២១២,០០ | ៤៦.៥៧៩,០០ | ៤៥.២០៣,០០ |
| សរុប I+II+III | | ១០៩.២១៣,២៣ | ២៤៦.៩៩៤,៨៥ | ៧៣.៩៨៨,៣៣ | ៦៥.៧៤២,៥០ |

- គួរកត់សម្គាល់ថា ក្នុងខែសីហា ឆ្នាំ២០១៥នេះ តម្លៃកៅស៊ូជាមធ្យមគឺ១.២២០ ដុល្លារក្នុងមួយតោន។

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- ចូលរួមកិច្ចប្រជុំពិសេសរបស់ IRRDB នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី
- ធ្វើតេស្តភាគសំណាកយថាប្រភេទបានចំនួន៤០ភាគសំណាក ដើម្បីបញ្ជាក់គុណភាពកែច្នៃកៅស៊ូរបស់រោងចក្រក្រុមហ៊ុន ឡុង ស្រេង និងសំណាកសម្រាប់និស្សិតកម្មសិក្សា
- វិភាគ DRC តាមមេត្រូឡាក់ តាមការជុតរក TSC និងការវិភាគស្តង់ដា Sucrose, Pi, R-SH
- ចុះស្រង់និងត្រួតពិនិត្យទិន្នន័យទឹកជ័រគ្រប់ចម្ការពិសោធន៍ និងបញ្ចូលទិន្នន័យចម្ការពិសោធន៍
- ចុះវាស់ទំហំដើមកៅស៊ូក្នុងឡូត៍ពិសោធន៍ក្លូននៅស្រុកស្វាយលើ ខេត្តសៀមរាប
- ក្រុមការងារច្បារពូជចុះយកសំណាកស្លឹកកៅស៊ូនៅខេត្តរតនគិរី និងខេត្តមណ្ឌលគិរី ដើម្បីវិភាគDNA
- ដាំជួសកូនកៅស៊ូលើចម្ការដាំឆ្នាំ២០១៥ និងរៀបចំថ្នាលបណ្តុះកូនឆ្នាំ២០១៥-២០១៦
- ដាក់ជីលើចម្ការពិសោធន៍ការប្រើប្រាស់ជីលើកៅស៊ូផ្តល់ផលតាមពិធីសារពិសោធន៍
- ដឹកនាំនិស្សិតសរសេរសារណាបទថ្នាក់បរិញ្ញាបត្រមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្ម សាកលវិទ្យាល័យស្វាយរៀង និងសាលាជាតិកសិកម្មកំពង់ចាម។

៣.១ **ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ការចុះតាមដានស្ថានភាពចិញ្ចឹមសត្វ និងណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងកំពុងកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តាខេត្តនិងរាជធានីរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត:

- **ការងារកែលម្អពូជ៖** ការកែលម្អពូជកំពុងតែឈានឆ្ពោះទៅមុខជាបណ្តើរ ព្រោះប្រជាកសិករភាគច្រើនកាន់តែមានការយល់ដឹងពីការជ្រើសរើសពូជសត្វដែលផ្តល់ទិន្នផលខ្ពស់ ការលូតលាស់ឆាប់រហ័ស ធន់នឹងជំងឺ និងផ្តល់ប្រាក់ចំណូលគ្រួសារខ្ពស់។

- **ការងារឡជីវៈឧស្ម័ន៖** ដោយមាការអភិវឌ្ឍន៍វិស័យចិញ្ចឹមសត្វ ការគ្រប់គ្រងកាកសំណល់ពីសត្វក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់តាមរយៈការអប់រំ ណែនាំ ផ្សព្វផ្សាយការអនុវត្តល្អប្រសើរការចិញ្ចឹមសត្វ ការសាងសង់ឡជីវឧស្ម័ននៅកសិដ្ឋានចិញ្ចឹមសត្វ និងនៅតាមគ្រួសារកសិករចិញ្ចឹមសត្វ។ ការសាងសង់ឡជីវឧស្ម័នថ្នាក់ជាតិបាននឹងកំពុងអនុវត្តយ៉ាងសកម្មដែលមកទល់ពេលនេះ ខេត្តដែលស្ថិតក្រោមការអនុវត្តកម្មវិធីឡជីវឧស្ម័នមាន ខេត្តកំពង់ចាម ស្វាយរៀង ព្រៃវែង តាកែវ កំពង់ស្ពឺ កណ្តាល កំពង់ឆ្នាំង កំពត សៀមរាប កំពង់ធំ ត្បូងឃ្មុំ និងពោធិ៍សាត់សម្រេចបាន១៩១ឡ(គិតត្រឹមខែកក្កដា ឆ្នាំ២០១៥) និងឡគម្រោងសាធារណរដ្ឋប្រជាមានិតចិនសម្រេចបាន១២០ (គិតត្រឹមថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៤) សរុបរួម៖ ៣១១ឡ។

- **ចំណីសត្វ៖** បច្ចុប្បន្ននេះមានការវិនិយោគលើការបង្កើតរោងចក្រចំណីសត្វសម្រាប់ផ្គត់ផ្គង់ក្នុងស្រុក ហើយបានកាត់បន្ថយការនាំចូលចំណីសត្វយ៉ាងច្រើន។ ដោយឡែកប្រជាកសិករមានការចូលរួមយ៉ាងសកម្មក្នុងការផលិត និងមានការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេចយ៉ាងផុសផុល។

- **ការងារដំណាំចំណីសត្វ៖** តាមបណ្តាខេត្តមួយចំនួនបានធ្វើសួនដំណាំចំណីសត្វ ព្រមទាំងផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ព្រមទាំងផ្តល់ពូជស្មៅដល់កសិករនិងភ្នាក់ងារសុខភាពសត្វភូមិ ក្រោមកិច្ចសហការជាមួយគម្រោងអន្តរជាតិដូចជា ACIAR និងCIAT ជាដើម។

### ៣.២ ការងារបសុពេទ្យបាល

- **លទ្ធផលត្រួតពិនិត្យនិងបង្ក្រាបបទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វ៖**

ខេត្ត-រាជធានីចំនួន១៧ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគនៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែង ចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទុះជំងឺសត្វចំនួន២.៧២១លើក។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យនិងបង្ក្រាប ដោយបានកប់និងកម្ទេចចោលផលិតផលសាច់ខូចគុណភាពតាមវិធានបសុពេទ្យចំនួន៥២៣,៤គីឡូក្រាម។ នៅខេត្តកំពតបានបង្ក្រាបបទល្មើសអាជីវកម្មពិឃាតជ្រូកខុសច្បាប់០១ករណី។

- **ការងារសុខភាពសាធារណៈ៖** ចុះត្រួតពិនិត្យទីតាំងស្នើសុំបង្កើតនិងបន្តសុពលភាពសត្តឃាតដ្ឋានប្រភេទ «ក» និង «ខ»តាមបណ្តារាជធានី-ខេត្ត និងចុះត្រួតពិនិត្យអនាម័យសត្តឃាតដ្ឋានឱ្យស្របតាមលក្ខណៈបច្ចេកទេស។

- **ការងារនីតិកម្មនិងវិវាទ៖** ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្ម បានប្រជុំពិភាក្សាលើសេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ដើម្បីពិនិត្យមើលឡើងវិញនូវចំណុចដែលមិនទាន់ស្របគ្នា។ បន្តរៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងកសិដ្ឋានចិញ្ចឹមសត្វ និងសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីកិច្ចសម្របសម្រួលក្នុងការបង្កើតនិងការគ្រប់គ្រងសត្តឃាតដ្ឋាន និងរៀបចំផែនការយុទ្ធសាស្ត្រវិស័យសុខភាពសត្វនិងផលិតកម្មសត្វរយៈពេល១០ឆ្នាំ (២០១៥-២០២៤)។

### ៣.៣ ការងារស្រាវជ្រាវ៖

- **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះគោសរុបមានចំនួន១៥៦ក្បាលក្នុងនោះគោបា៣ក្បាល គោប្រាម៉ាន់កាត់៣៥ក្បាល គោជំទង់៣៤ក្បាល គោបៅដោះ៤២ក្បាល គោកំផែងសែន៤២ក្បាល គោកើតថ្មី៤ក្បាល និងគោលក់៤ក្បាល។ ចំណែកការងារពិសោធន៍ពូជជ្រូកកម្ពុជា-ចិនជ្រូកសរុប២៤៧ក្បាល ក្នុងនោះជ្រូកបាចំនួន៩ក្បាល ជ្រូកមេ៨៨ក្បាល កូនជ្រូក១៥០ក្បាល ក្នុងនោះកូនជ្រូកលក់១០០ក្បាល និងកូនជ្រូកងាប់១៧ក្បាល។ ការបង្កាត់ពូជតាមបែបសិប្បនិម្មិតនិងធម្មជាតិប្រព្រឹត្តទៅជាប្រក្រតី និងផ្សព្វផ្សាយបច្ចេកទេសបន្តទៅដល់កសិករ។

•ការងារស្រាវជ្រាវបសុព្យាបាលៈ ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែបានយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺនិងងាប់ ដើម្បីវិភាគរកប្រភេទមេរោគបង្កជំងឺជាពិសេសមេរោគជំងឺផ្តាសាយបក្សី មេរោគជ្រូកត្រចៀកខៀវជាដើម។ ជាក់ស្តែងក្នុងខែសីហាឆ្នាំ២០១៥នេះ បានពិនិត្យវត្ថុវិភាគសរុបចំនួន១០១វត្ថុវិភាគ។

៣.៤ **ការងារផ្សព្វផ្សាយបច្ចេកទេសៈ** ចងក្រងឯកសារការងារផលិតកម្មនិងបសុព្យាបាលសម្រាប់ចុះក្នុងទស្សនាវដ្តី រៀបចំកម្មវិធីផ្សព្វផ្សាយបច្ចេកទេសផលិតកម្មនិងបសុព្យាបាល ជាពិសេសផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីជំងឺផ្តាសាយបក្សី ជំងឺជ្រូកត្រចៀកខៀវ និងជំងឺផ្សេងៗទៀតដែលអាចកើតឡើងជាយថាហេតុ។

## ៤ ផ្នែករុក្ខាប្រមាញ់ / ព្រៃឈើ

### ៤.១ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

- ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង កំពង់ធំ និងសៀមរាប) ដែលមានសត្វស្លាបប្រមាណ៤៣៧ប្រភេទ (ប្រហែល៤៤.៤៩៥ក្បាល)

- ប្រមូលសំណាកសត្វប្រចៀវរស់បានចំនួន១០០ក្បាល ដើម្បីធ្វើការពិនិត្យទៅលើឈាម លាមក ទឹកមាត់ ទឹកនោម និងវាស់ប្រវែងស្លាបដើម្បីវិភាគរកមេរោគនិងការបន្តពូជ និងសិក្សាស្រាវជ្រាវលើភ្នំចំនួន២ដែលរកឃើញល្អាងចំនួន១៣ និងបានរកឃើញប្រចៀវចំនួន៤ប្រភេទៈ Rhinolopus, Megaderma, Chaerephon និង Hipposideros

- ផ្តល់ចំណីដល់សត្វត្មាតនៅស្ទឹងត្រែង ក្រចេះ ដោយរាប់ឃើញត្មាតសរុបប្រមាណ១៣ក្បាល

- ការពារសម្បុកសត្វត្រយ៉ងចង្កំ ក សចំនួន១ នៅខេត្តស្ទឹងត្រែង និងក្រចេះ។ មូលហេតុដែលត្រូវការពារសម្បុកសត្វព្រោះប្រភេទសត្វទាំងនេះមានមាឌធំងាយស្រួលក្នុងការចាប់យកកូន ឬប្រមូលយកពងពីសំណាក់ប្រជាជនមូលដ្ឋាន ហើយសត្វស្លាបប្រភេទនេះជិតផុតពូជនិងមានដោយកម្រ

- បន្តការល្បាតដោយក្រុមល្បាតសហគមន៍ចំនួន២២នាក់ នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៤គឺនៅអារ៉ែងឆាយរាប តំបន់ស្តារក្រពើក្នុងឃុំតាតៃលើ ខេត្តកោះកុង និងអូរសោម ខេត្តពោធិ៍សាត់

- កំពុងថែរក្សាតំបន់ព្រៃការពារទំហំ ១.៦២៨.០៩៥ហិកតា ដើម្បីការពារធនធានព្រៃឈើ និងជីវចម្រុះ ដែលរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្ររបស់សហគមន៍មូលដ្ឋាន តាមរយៈការប្រមូលផល អនុផលព្រៃឈើការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងរួមចំណែកដល់ការធ្វើនិយតកម្មប្រភពទឹកសម្រាប់វារីអគ្គិសនី ដែលមានលទ្ធភាពផលិតចំនួនជិត ១០០០ មេហ្គាវ៉ាត់ នៅតំបន់ជួរភ្នំក្រវាញដើម្បីជួយលើកកម្ពស់កំណើនសង្គមសេដ្ឋកិច្ចជាតិ និងផ្តល់សេវាកម្មបរិស្ថានដល់សាធារណជន ទឹកសាបសម្រាប់ប្រើប្រាស់ និងស្រោចស្រពដំណាំកសិកម្ម

- កំពុងរៀបចំអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិច រុក្ខជាតិ និងសត្វព្រៃព្រះរការ ដែលមានទំហំ ៩២.១៣២ហិកតា ក្នុងខេត្តព្រះវិហារ

- រៀបចំផែនការគ្រប់គ្រងតំបន់ព្រៃការពារមណ្ឌលគិរី

- មានភ្ញៀវទេសចរបរទេសចំនួន១៧នាក់មកទស្សនាតំបន់អភិរក្សជីវចម្រុះវ៉ុនសៃ-សៀមប៉ាង អាងត្រពាំងថ្ម សីម៉ា កំពង់ធំ និងសៀមរាប។

### ៤.២ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- សម្រាប់ខែសីហា ឆ្នាំ២០១៥នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹមនិងថែរក្សាៈ សង្គ្រោះសត្វព្រៃថ្មីគ្រប់ប្រភេទចំនួន៧៤ក្បាល សត្វកើតថ្មីចំនួន៤ក្បាល និងព្យាបាលសត្វចំនួន៣៩៤ក្បាល

- ក្រុមហ៊ុនចំនួន៦ គ្រប់គ្រងកសិដ្ឋានចំនួន៧ កំពុងចិញ្ចឹមស្វាក្តាមចំនួន៥៣.២៤១ក្បាល។

### ៤.៣ ការងារសហគមន៍ព្រៃឈើ

- រៀបចំសេចក្តីព្រាងប្រកាសស្តីពីការបង្កើតនិងការគ្រប់គ្រងតំបន់ព្រៃសហគមន៍ក្នុងខេត្តស្ទឹងត្រែងចំនួន១សហគមន៍ព្រៃឈើគ្របដណ្តប់លើផ្ទៃដីទំហំ១.០៧៣ហិកតា

- ចេញប្រកាសទទួលស្គាល់សហគមន៍ព្រៃឈើស្ថិតនៅក្នុងខេត្តចំនួន៣ ដែលមាន៣៣សហគមន៍ព្រៃឈើ ស្មើនឹង ៣៤កន្លែង មានផ្ទៃដីសរុបទំហំ៨.១១៥ហិកតា

- កែសម្រួលសេចក្តីព្រាងផែនការគ្រប់គ្រងសហគមន៍ចំនួន១ ក្នុងខេត្តពោធិ៍សាត់

- រៀបចំសិក្ខាសាលាស្តីពីការបង្កើតគណៈកម្មការសម្របសម្រួលកម្មវិធីសហគមន៍ព្រៃឈើថ្នាក់ខេត្តចំនួន២គឺ ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ដែលមានអ្នកចូលរួមចំនួន៩៣នាក់ (ស្រី១០នាក់)។

### ៤.៤ ការងារដាំដើមឈើ

- ការដាំឈើជាចម្ការថ្មីនៅតាមបណ្តាស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើរបស់រដ្ឋបាលព្រៃឈើចំនួន៣(ស្ថានីយយុនរាម ក្បាលឆាយបានបញ្ចប់ការដាំដុះ និងស្ថានីយអូរបឹងរូងបានបញ្ចប់ការឈូសឆាយនិងបន្តការដាំដុះ) ដោយឈូសឆាយដីព្រៃបានចំនួន១៣ហិកតា និងដាំកូនក្រញូងសរុបចំនួន១០៧ហិកតា

- ថែទាំចម្ការឈើឆ្នាំទី១ដល់ឆ្នាំទី៥ ដែលមានផ្ទៃដីទំហំ២.៨១៨ហិកតា នៅស្ថានីយដាំឈើចំនួន១៦ និងបានថែទាំដាំជួស និងធ្វើអនាម័យ ជាពិសេសគឺទប់ស្កាត់ការរុករានចម្ការឈើ និងភ្លើងព្រៃ

- បណ្តុះកូនឈើសម្រាប់ចែកជូនកសិករដាំអាស្រ័យផលបានចំនួន២៦៦.៤០៥ដើម និងចែកជូនប្រជាកសិករដាំចំនួន១៩៨.២៤២ដើម។

### ៤.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើចំនួន៣ក្រុមហ៊ុនគឺ៖

  + ក្រុមហ៊ុន ស៊ីវហ្គេក អ៊ិនវេសមេន នៅខេត្តស្ទឹងត្រែង ក្នុងអនុតំបន់V មានផ្ទៃដីទំហំ៩០០ហិកតា អនុតំបន់VI មានផ្ទៃដីទំហំ៨៤៥ហិកតា និងអនុតំបន់ VIIA មានផ្ទៃដីទំហំ៥៥៨ហិកតា

  + ក្រុមហ៊ុនដូទីសាយហ្គុន ប៊ិញហ្វឿក(អេស ប៊ី ខេ) នៅខេត្តក្រចេះ ក្នុងអនុតំបន់III មានផ្ទៃដីទំហំ៣.៣៦៤ហិកតា និងអនុតំបន់IV មានផ្ទៃដីទំហំ១.៨៣៩ហិកតា

  + ក្រុមហ៊ុន ស៊ី&វី នៅខេត្តក្រចេះ ក្នុងអនុតំបន់VI មានផ្ទៃដីទំហំ១.០៦៤ហិកតា និងអនុតំបន់VII មានផ្ទៃដីទំហំ២៦៣ហិកតា

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលឈើកែច្នៃជូនក្រុមហ៊ុនចំនួន២ ដែលមានបរិមាណឈើកែច្នៃចំនួន ៣.៤១៥ម៣

- ផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចូលផលិតផលឈើកែច្នៃជូនក្រុមហ៊ុនចំនួន១ ដែលមានបរិមាណឈើកែច្នៃចំនួន២៨ម៣

- ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុនចំនួន៥ និងអតិថិជនចំនួន៦នាក់ ដែលមានឈើហ៊ុបមូលសរុបចំនួន១១.៣៧១ម៣ ឈើជ្រុងចំនួន៣២៦ម៣ កូនឈើចំនួន១៥១.៧៥៥ដើម អុសចម្រុះចំនួន ១៨.០៧០ស្ទែរ និងជ័រទឹកចំនួន៥៥៦តោន

- ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើសម្រាប់នាំចេញជូនក្រុមហ៊ុនចំនួន២ ស្មើនឹង៣១សន្លឹក ដែលមានបរិមាណឈើចំនួន៣.២៣៤ម៣។

### ៤.៦ ការងារចំណូលព្រៃឈើ

- សម្រាប់ខែសីហា ឆ្នាំ២០១៥នេះចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន៥០៦.៨៦០.៥៣១រៀល និងចំណូលពីសេវាសាធារណៈចំនួន៥៩៤.៤៤៨.០០២រៀល និង៣១.៣៥៦ដុល្លារ។

### ៤.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែសីហា ឆ្នាំ២០១៥នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃ នៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន១៥៥ករណី ដោយបញ្ជូនទៅតុលាការចំនួន៧៥ករណី និងពិន័យអន្តរការណ៍ចំនួន៨០ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន២៨ម៣ ឈើអារចំនួន៣១៤ម៣ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន៤៧៤ក្បាលនិង៧៧គ.ក្រ និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន៧៤ហិកតា ត្រូវបានបញ្ជូនសំណុំរឿងទៅតុលាការ និងដកហូតរណារយន្តចំនួន៧គ្រឿង

- បន្តដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ(Case Tracking System-CTS) ដើម្បីរៀបចំឱ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ចុះពង្រឹងការអនុវត្តច្បាប់ ដោយចុះត្រួតពិនិត្យរោងសន្និធិទិញ-លក់ផល អនុផលព្រៃឈើចំនួន ១១កន្លែង នៅក្នុងនោះខេត្តកំពង់ធំចំនួន៨កន្លែង និងសៀមរាបចំនួន៣កន្លែង។ ជាលទ្ធផលរោងសន្និធិចំនួន៧កន្លែង ត្រូវ បានរកឃើញមានបរិមាណឈើលើសក្នុងស្តុក ដែលក្នុងនោះខេត្តកំពង់ធំចំនួន៤កន្លែងមានឈើអារសរុបចំនួន ១៨,៣៧៧ម៣ ( ឈើអារប្រភេទលេខ១ ចំនួន៥,៣១០ម៣ ឈើអារប្រភេទលេខ ២ ចំនួន១២,២៣៧ម៣ និងមានឈើអារក្រៅលំដាប់ថ្នាក់ចំនួន០,៨៣០ម៣ ) និងខេត្តសៀមរាបចំនួន២កន្លែង មានឈើអារប្រភេទលេខ២ សរុបចំនួន៦,៦៣៣ម៣។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

៥.១.១ នេសាទទឹកសាប

- ដាយត្រីធ្វើអាជីវកម្ម សរុបរយៈពេល៨ខែបានចំនួន១២.២៨៥តោន ស្មើ១០២,៣៨% នៃផែនការ១២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១១.៧១៥តោន (បញ្ចប់រដូវ)

- នេសាទគ្រួសារក្នុងដែននេសាទ ក្នុងខែសីហា អនុវត្តបានចំនួន១៥.០០០តោន ។ សរុបរយៈពេល៨ខែបានចំនួន២០០.២៥០តោន ស្មើ៥៧,២១% នៃផែនការ៣៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៤.៧៥០តោន

- នេសាទគ្រួសារតាមវាលស្រែ ក្នុងខែសីហា អនុវត្តបានចំនួន១៥.០០០តោន សរុបរយៈពេល៨ខែបានចំនួន៦៩.១៥៥តោន ស្មើ៤៦,១០% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៥.៨៤៥តោន (មូលហេតុនៃការថយចុះគឺបណ្តាលមកពីការប្រែប្រួលអាកាសធាតុ)។

៥.១.២ នេសាទសមុទ្រ

- ក្នុងខែសីហា អនុវត្តបានចំនួន៩.០០០តោន សរុបរយៈពេល៨ខែចំនួន៦៩.០០០តោន ស្មើ៦២,៧៣% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១.០០០តោន។

### ៥.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គា ក្នុងខែសីហា អនុវត្តបានចំនួន១៧.០០០តោន សរុបរយៈពេល៨ខែបានចំនួន៩៦.០៥០តោន ស្មើ៦៦,៧០% នៃផែនការ១៤៤.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន៣១,០៥០តោន

- ការចិញ្ចឹមក្រពើ ក្នុងខែសីហា អនុវត្តបានចំនួន២០.០០០ក្បាល សរុបរយៈពេល៨ខែ បានចំនួន១៧៥.៥០០ក្បាល ស្មើ៧០,២០% នៃផែនការ២៥០.០០០ក្បាល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន២៤.៥០០ក្បាល

- ការភ្ញាស់កូនត្រីពូជ ក្នុងខែសីហា អនុវត្តបានចំនួន២០.០០០.០០០កូន សរុបរយៈពេល៨ខែ បានចំនួនប្រមាណ១២៥.០០០.០០០កូន ស្មើ៦៩,៤៤% នៃផែនការ១៨០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួនប្រមាណ២៥.០០០.០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៤-២០១៥ ក្នុងខែសីហា អនុវត្តបានចំនួន៤.០០០តោន សរុបរយៈពេល៨ខែបានចំនួន៤១.៥០០តោន ស្មើ៥០,៦១% នៃផែនការ៨២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៥.៥០០តោន

- ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៥ ក្នុងខែសីហា អនុវត្តបានចំនួន១.០០០តោន សរុបរយៈពេល៨ខែបានចំនួន៧.៣០០តោន ស្មើ៩១,២៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន១.១០០តោន

- ការផលិតទឹកត្រីក្នុងខែសីហា អនុវត្តបានចំនួន៤.០០០.០០០លីត្រ សរុបរយៈពេល៨ខែបានចំនួន៤៧.០០០.០០០លីត្រ ស្មើ៩៤% នៃផែនការ៥០.០០០.០០០លីត្រ ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៥.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ ក្នុងខែសីហា អនុវត្តបានចំនួន៥០០តោន សរុបរយៈពេល៨ខែបានចំនួន៦.៦០០តោន ស្មើ៤៤% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១.១០០តោន

- ផលនេសាទកែច្នៃ ក្នុងខែសីហា អនុវត្តបានចំនួន៣០០តោន សរុបរយៈពេល៨ខែបានចំនួន៣.៤០០តោន ស្មើ៦៨% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៧០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- ក្នុងខែសីហា ឆ្នាំ២០១៥នេះ សំណុំរឿងបទល្មើសជលផល មានចំនួន៣៣៧ករណី ក្នុងនោះបទល្មើសទឹកសាប ចំនួន៣២១ករណី និងបទល្មើសសមុទ្រចំនួន១៦ករណី

- បានផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានក្រោមច្បាប់ពាក់ព័ន្ធចំនួន៥២វគ្គ ដោយមានអ្នកចូលរួមចំនួន៣.៩៩៧នាក់

- ចុះរុះរើនិងបំផ្លាញចោលវត្ថុតាងបទល្មើសជលផលរួមមាន៖ របាំងស្បៃមុងនិងសាច់អួនប្រវែង៩២.៤៩១ម៉ែត្រ លូស្បៃមុងនិងសាច់អួនចំនួន១.៦១០មាត់ បង្គោល/ចម្រឹងចំនួន១៨៨.២៣២ដើម ឧបករណ៍ឆក់ត្រីចំនួន២៨គ្រឿង សម្រាស់ចំនួន២៤០ម៉ែត្រក្រឡា របាំងព្រួលប្រវែង២.២៣៧ម៉ែត្រ លបកែច្នៃ(កន្ទុយកណ្ដុរ/ពោះវៀនជ្រូក)ចំនួន១១៦ គ្រឿង លែងត្រីចម្រុះចូលក្នុងបឹងធម្មជាតិចំនួន៥៨.០៩៨គ.ក្រ កូនត្រីឆ្ដោចំនួន៦៩.៤០០ក្បាល និងកូនត្រីរ៉ស់ចំនួន ១៦០.០០០ក្បាល

- ថ្នាក់ដឹកនាំក្រសួងរួមទាំងសមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព រួមទាំងការទប់ស្កាត់ការលួចចិញ្ចឹមត្រីរ៉ស់និងត្រីឆ្ដោផងដែរ។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផល មកទល់ពេលនេះសរុបបានចំនួន២.៣៥៤.៥៥១.៧៧៥រៀល ស្មើ៦៦,២៥% នៃផែនការ៣.៥៥៤.២៨១.២៥០រៀល (សម្រាប់រយៈពេល៨ខែដើមឆ្នាំ) ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១៣៦.៣៦៨.៩៥៧រៀល។ ដោយឡែក ក្នុងខែសីហា ឆ្នាំ២០១៥ អនុវត្តបានចំនួន១៨៦.១៤២.០០០រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះតាមដាន រៀបចំថ្នាលសំណាប រៀបចំស្តូងពិសោធន៍ និងពិនិត្យពិសោធន៍ នៅខេត្តតាកែវ និងខេត្តព្រៃវែង
- ចុះសម្ភាសន៍កសិករនិងត្រួតពិនិត្យការងារពិសោធន៍នៅខេត្តកណ្ដាល
- ត្រួតពិនិត្យស្ថានភាពដាំដុះ និងភាពរាំងស្ងួតរបស់ដំណាំនៅខេត្តកំពង់ធំ
- ចុះពិនិត្យមើលការងារពិសោធន៍ស្រាវជ្រាវនៅខេត្តស្ទឹងត្រែង និងខេត្តសៀមរាប
- ចុះធ្វើអង្កេត តាមដាន និងប្រមូលព័ត៌មានពីកសិករនៅខេត្តបាត់ដំបង
- ចុះធ្វើទិវាស្រែបង្ហាញដែលមានអ្នកចូលរួមសរុបចំនួន៥៣នាក់ នៅខេត្តតាកែវ។

## ៧ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៤៨១ច្បាប់ (សរុបរយៈពេល៨ខែចំនួន៣.៧៧៦ច្បាប់) ទទួលពីអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៤៣១ច្បាប់ (សរុបរយៈពេល៨ខែចំនួន២.៧៤៥ច្បាប់) និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន១៤៨ច្បាប់ (សរុបរយៈពេល៨ខែចំនួន១.១០៣ច្បាប់) និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៨០៧ច្បាប់ (សរុបរយៈពេល៨ខែចំនួន៥.៨៤៨ច្បាប់) ប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន៥០ច្បាប់ (សរុបរយៈពេល ៨ខែចំនួន៤៤៩ច្បាប់) ចម្លងចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន៣៧ច្បាប់ (សរុបរយៈពេល៨ខែចំនួន២២២ច្បាប់) និងផ្ដល់ទិដ្ឋាការបេសកកម្មចំនួន១៥ច្បាប់ សរុបមនុស្ស៣០នាក់

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ។ល។

## ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៧៣៧នាក់ នារីចំនួន១.៣៥៤នាក់ ស្មើនឹង២០% រួមមាន៖

+ អង្គភាពថ្នាក់កណ្ដាលចំនួន៤.១០៥នាក់ ក្នុងនោះនារីចំនួន៧៨១នាក់ ស្មើនឹង១៩%

+ អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦៣២នាក់ ក្នុងនោះនារីចំនួន៥៧៣នាក់ ស្មើនឹង២១,៧៧%

- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន០៥នាក់ ក្នុងនោះសុំលាឈប់ពីការងារចំនួន០១នាក់ និងមរណភាពចំនួន០៤នាក់

- ចេញច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន០៣នាក់ ច្បាប់ព្យាបាលជំងឺចំនួន០២នាក់ និងច្បាប់សម្រាកមាតុភាពចំនួន០៣នាក់

- ប្រកាសផ្ទេរមន្ត្រីរាជការចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន០១នាក់ និងប្រកាសព្យួរការងារមន្ត្រីរាជការចំនួន៣០នាក់

- បញ្ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមវគ្គបណ្ដុះបណ្ដាលក្រៅប្រទេសចំនួន៥០នាក់

- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្ដាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ៩ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្ដុះបណ្ដាល និងទស្សនកិច្ចសិក្សាសរុបចំនួន៧០រូប នៅប្រទេសចំនួន១៧ និងស្នើសុំលិខិតឆ្លងដែនផ្លូវការជូនមន្ត្រី០១រូប

- លើកសំណើសុំអ្នកជំនាញការសាធារណរដ្ឋកូរ៉េចំនួន២រូប ដែលមានជំនាញនិងបទពិសោធន៍ផ្នែកបង្កាត់ពូជគោ និងផ្នែកវិភាគកាកសំណល់ថ្នាំសត្វ

- ចូលរួមនិងរៀបចំកិច្ចប្រជុំផ្សេងៗជាអាទិ៍ កិច្ចការ ASEAN និងកិច្ចសហប្រតិបត្តិការជាមួយដៃគូផ្សេងៗទៀត

- ចូលរួមត្រួតពិនិត្យនិងវាយតម្លៃសកម្មភាពនៃការអនុវត្តគម្រោងរបស់អង្គការមួយចំនួនដែលចុះកិច្ចព្រមព្រៀងជាមួយក្រសួង។

## ១០ ការងារអប់រំ បណ្ដុះបណ្ដាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបចំនួន១.២២៣នាក់(ស្រី៣៩៦នាក់) ក្នុងនោះនិស្សិតបរិញ្ញាចំនួន១.០១៥នាក់(ស្រី៣៥០នាក់) និងនិស្សិតបរិញ្ញារងចំនួន២០៨នាក់(ស្រី៤៦នាក់) ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម និងកសិឧស្សាហកម្ម។ បន្តសហការជាមួយក្រសួងអប់រំយុវជននិងកីឡាក្នុងការកែលម្អកម្មវិធីសិក្សាក្នុងគោលបំណងប្រែក្លាយសាលាជាតិកសិកម្មព្រែកលៀបទៅជាសាកលវិទ្យាល័យជាតិព្រែកលៀប។ សាលាជាតិបាននិងកំពុងបំពាក់ប្រព័ន្ធអ៊ីនធឺណែត និងដំឡើងស័រវ័រ(Sever) ព្រមទាំងសហការយ៉ាងជិតស្និទ្ធជាមួយភាគីចិនក្នុងការសាងសង់អគារមន្ទីរពិសោធន៍ដែលគ្រោងនឹងបញ្ចប់នៅចុងឆ្នាំនេះ។

### ១០.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបមានចំនួន១.២១៨នាក់(ស្រី៤៥៨នាក់) រួមមាន៖

- និស្សិតអាហារូបករណ៍សរុប៨៤៨នាក់ (ស្រី៣៤១នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៦៩០នាក់(ស្រី២៤១នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម១៥៨នាក់(ស្រី១០០នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

- និស្សិតសិក្សាបង់ថ្លៃ២២៨នាក់ (ស្រី៦៧នាក់) ថ្នាក់បរិញ្ញាចំនួន២១៧នាក់(ស្រី៦៦នាក់) និងថ្នាក់បរិញ្ញារងចំនួន១១នាក់ (ស្រី១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។

### ១០.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតកំពុងសិក្សាមានចំនួនសរុប៥.៩៧៧នាក់(ស្រី១.៤០០នាក់) ចែកចេញជា១០មហាវិទ្យាល័យ គឺមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិង

រដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមដើម្បីបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- បើកវេទិកាសុខភាពតែមួយសម្រាប់កម្ពុជាឆ្នាំ២០១៥ ដែលមានអ្នកចូលរួមទាំងថ្នាក់ជាតិនិងអន្តរជាតិចំនួន ២០០នាក់ និងបើកវគ្គបណ្តុះបណ្តាលអំពីត្រីលើប្រធានបទ "ពីសំណាញ់ដល់ស្លាបព្រា" ជូនដល់និស្សិតមកពីសាធារណរដ្ឋឆេក្ក និងនិស្សិតមកពីសាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ ដែលមានរយៈពេល២សប្តាហ៍

- រៀបចំធ្វើសន្និសីទអន្តរជាតិស្តីពីបច្ចេកវិជ្ជាក្រោយពេលប្រមូលផលផ្នែកសាកវប្បកម្មនៅខេត្តសៀមរាប ដែលមានអ្នកចូលរួមទាំងថ្នាក់ជាតិនិងអន្តរជាតិចំនួន១៥០នាក់

- បញ្ជូនមន្ត្រីសាស្ត្រាចារ្យចំនួន៨រូប និងនិស្សិតចំនួន១៧រូប ចូលរួមវគ្គបណ្តុះបណ្តាលអន្តរជាតិនៅសាកលវិទ្យាល័យដៃគូនៅប្រទេសជប៉ុន ថៃ កូរ៉េ និងប្រទេសសឹង្ហបូរី

- សហការជាមួយមជ្ឈមណ្ឌល Kopia កម្ពុជា សម្របសម្រួលនិងដឹកនាំកសិករនិងសហគមន៍ឆ្នើមចំនួន៦នាក់ និងកសិករគំរូក្នុងគម្រោងចិញ្ចឹមមាន់បង្ហាញមកពីខេត្តកណ្តាល និងខេត្តតាកែវចំនួន១៤នាក់ទៅទស្សនកិច្ចសិក្សានិងចូលរួមវគ្គបណ្តុះបណ្តាលអំពីចលនាភូមិថ្មីនៅសាធារណរដ្ឋកូរ៉េចំនួន១សប្តាហ៍

- ទទួលអ្នកជំនាញការកូរ៉េចំនួន២នាក់មកពីអង្គការ KOICA (រយៈពេល១ឆ្នាំ)។

គ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើ តែងតែបញ្ជូននិស្សិតឱ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញនៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដូចខែមុនៗដែរដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការបង្ហាត់ឱ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិ-ពាណិជ្ជកម្ម រួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូឱ្យកាន់តែទូលំទូលាយ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួម នៅក្នុងខែសីហា ឆ្នាំ២០១៥នេះ ដំណើរការការងារបង្កបង្កើនផលស្រូវរដូវវស្សានៅទូទាំងប្រទេសសម្រេចបានចំនួន២.១២៣.៦២៩ហិកតា ស្មើនឹង៨២,៧២% នៃផែនការ២.៥៦៧.១៣០ហិកតា (តិចជាងឆ្នាំមុន៦០.៧៥១ហិកតា គិតក្នុងរយៈពេលដូចគ្នា)។ មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងបានធ្លាក់រាយប៉ាយល្អនៅទូទាំងប្រទេស តែនៅតាមតំបន់ខ្លះ ភ្លៀងធ្លាក់តិចតួចនិងពុំមានទឹកគ្រប់គ្រាន់នៅឡើយ។ ខេត្តដែលដាំដុះបានលឿនជាងគេគឺខេត្តបន្ទាយមានជ័យ ១០០,៨៣% ហើយខេត្តដែលអនុវត្តបានតិចជាងគេគឺខេត្តប៉ៃលិន៥៥,១៨%។

គួរកត់សម្គាល់ថា ការភ្ជួររាស់ដោយគ្រឿងយន្តក្នុងទូទាំងប្រទេសមានអត្រាប្រមាណ៨៩,៥៩%។ រីឯការភ្ជួររាស់ដោយកម្លាំងសត្វពាហនៈនៅសល់ក្រោម១០,៤១% ប៉ុណ្ណោះ។ ឆ្នាំនេះ ប្រជាកសិករចូលចិត្តបង្កបង្កើនផលស្រូវដោយព្រោះយកតែម្តងច្រើនជាងការដកស្ទូង ម្យ៉ាងមកពីការរាំងស្ងួតអូសបន្លាយយូរនៅដើមរដូវ និងដោយសារខ្វះកម្លាំងពលកម្មផងដែរ។ ដោយឡែក ចំពោះជំងឺឆ្លងសត្វមានកើតឡើងនូវជំងឺជ្រូកត្រចៀកខៀវ (Porcine Reproductive Repiratory Syndrom : PRRS)នៅខេត្តសៀមរាប ខេត្តកំពង់ចាម និងខេត្តស្វាយរៀង។ ករណីនេះ ក្រសួងបានចេញប្រកាសកំណត់តំបន់ផ្ទុះជំងឺនិងបានចាត់អង្គភាពជំនាញនាយកដ្ឋានផលិតកម្មនិងបសុព្យាបាលសហការជាមួយមន្ត្រីបសុពេទ្យខេត្ត ស្រុក និងអាជ្ញាធរថ្នាក់ក្រោមជាតិ ដើម្បីចាត់វិធានការជីវសុវត្ថិភាព និងតាមដានត្រួតពិនិត្យ នៅតាមតំបន់ដែលផ្ទុះជំងឺដោយបាញ់ថ្នាំសម្លាប់មេរោគ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលទៅកន្លែងដទៃទៀត។

ចំពោះការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល គឺស្ថិតនៅតែជាប្រធានបទអាទិភាព ដែលអង្គភាពជំនាញជាសេនាធិការនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញការចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែងដើម្បីលុបបំបាត់បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាពពិតមែនតែនៅជួបប្រទះបញ្ហាប្រឈមខ្លះៗក៏ដោយ។ លើសពីនេះទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់តាមផ្នែកសំខាន់ផ្សេងៗ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មជី-ថ្នាំកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល។

IV- **ទិសដៅអនុវត្តបន្ត**

**១.ផ្នែកដាំដុះ** :

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗនិងជំរុញការងារបង្កបង្កើនផលរដូវវស្សានេះឱ្យបានសម្រេចតាមផែនការ

- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ដើម្បីស្តារការដាំដុះឡើងវិញឱ្យបានទាន់ពេលវេលានៅតំបន់ដែលទទួលរងការខូចខាតដោយគ្រោះរាំងស្ងួត ព្រមទាំងត្រៀមបម្រុងគ្រាប់ពូជស្រូវសម្រាប់ផ្តល់ជូនកសិករក្រីក្រដែលពុំមានលទ្ធភាពទិញគ្រាប់ពូជ ជាពិសេសចំពោះខេត្តដែលមានអត្តុល្យភាពស្បៀង (អង្ករ) ដោយជំរុញកសិករឱ្យធ្វើការដាំដុះស្រូវស្រាលឬស្រូវកណ្តាល ដើម្បីកាត់បន្ថយផលប៉ះពាល់បង្កដោយគ្រោះរាំងស្ងួត គ្រោះខ្វះទឹកដែលអាចកើតឡើងជាយថាហេតុនៅចុងរដូវ និងដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឱ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជា៖ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារនានាសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសទៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តស្រាវជ្រាវការដាំដុះសាកល្បងក្លូនកៅស៊ូប្រភេទ "Invitro" និងបន្តផ្សព្វផ្សាយអំពីបច្ចេកទេសដ៏មានសារសំខាន់នេះក្នុងក្របខណ្ឌនៃគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា

- ការត្រៀមលក្ខណៈដើម្បីរៀបចំកិច្ចប្រជុំ និងសន្និសីទកៅស៊ូប្រចាំឆ្នាំ២០១៥ របស់សមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ។

**២.ផ្នែកផលិតកម្មនិងបសុព្យាបាល** :

- បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានជាបន្តលើសភាពការណ៍ជំងឺជ្រូកត្រចៀកខៀវ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ រួមទាំងមន្ទីរកសិកម្មរាជធានី ខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាលសង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ ទន្ទឹមនឹងនោះ ក៏បានបន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀតព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឱ្យបានទូលំទូលាយ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឱ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

**៣.ផ្នែកព្រៃឈើ** :

- បន្តជំរុញដាក់ឱ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការ

ពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឱ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឱ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើ និងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើ សត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឱ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឱ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឱ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២។

**៤.ផ្នែកជលផល** :

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឱ្យបានគ្រប់ឃុំ

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៥ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

**៥.ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្តាខេត្ត រាជធានី។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មខេត្ត រាជធានី ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញនៅឆ្នាំ២០១៥ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឱ្យបានទូលំទូលាយ។ ទន្ទឹមនឹងនេះ ក៏បានគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ពង្រឹងការគ្រប់គ្រងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់ឱ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងអភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទាំងក្នុងនិងក្រៅប្រទេស

- ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត អត្ថបទក្រោមច្បាប់ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ ស្តង់ដារ គោលការណ៍ និងហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទ ដើម្បីអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជាពីកសិកម្មបែបវិបុលកម្ម មានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់និងផលិតសម្រាប់ធ្វើពាណិជ្ជកម្មក្នុងការត្រៀមលក្ខណៈសមាហរណកម្មចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំ២០១៥ និងនាពេលអនាគត។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

អ៊ុក រ៉ាប៊ុន